# សេចក្តីសំរេច លេខ ០៦ សសរ

# ស្តីពី

# ការបង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ

~~~

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងស្មារតីនៃជំនួបមិត្តភាពក្រៅផ្លូវការនៅវៀងច័ន្ទ រវាងនាយករដ្ឋមន្ត្រី កម្ពុជា-វៀតណាម-ឡាវ នាថ្ងៃ ១៩-២០ តុលា ១៩៩៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **ស៊ុន សារឿន** | អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ជាប្រធាន |
| ២-លោក | **លាភ វណ្ណដេន** | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-លោក | **ឡុង គែម** | ប្រធាននាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក ក្រសួងការបរទេស | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-លោក | **លឹម សំគុល** | ប្រធាននាយកដ្ឋានទំនាក់ទំនង អន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

www.pheakdeylaw.com
~~~

៥-លោក **នុត ចន្ទសុខា** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិក្រសួងផែនការ សមាជិក

៦-លោក **ទ៉ា ស៊ីមសូរិយ៉ា** ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៧-លោក **សុខ សុគន្ធា** ប្រធាននាយកដ្ឋានអាស៊ាននិងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម សមាជិក

៨-លោក **ប៊ុន ណារិទ្ធ** ប្រធាននាយកដ្ឋានវារីអគ្គិសនី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៩-លោក **សៅ ជីវ័ន្ត** ប្រធានស្តីទីនៃនាយកដ្ឋានផែនការនិងទំនាក់ទំនងអន្តរជាតិ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១០-លោក **សារ ណារ៉ាត់** អនុប្រធាននាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១១-លោក **នួត សារ៉ាវុធ** អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សមាជិក

១២-លោកវេជ្ជបណ្ឌិត **ឡូ វាសនាគីរី** អនុប្រធាននាយកដ្ឋានផែនការស្ថិតិ ផែនការនិងពត៌មានសុខាភិបាលក្រសួងសុខាភិបាល សមាជិក

**ប្រការ ២** : គណៈកម្មការនេះ មានបេសកកម្មដូចខាងក្រោម :

- សិក្សាស្រាវជ្រាវ និងពិចារណាធ្វើយ៉ាងណាដើម្បីអភិវឌ្ឍន៍តំបន់ត្រីកោណ រវាងប្រទេសទាំងបី កម្ពុជា-វៀតណាម-ឡាវ លើផ្នែកបរិស្ថាន កសិកម្ម និងរចនាសម្ព័ន្ធផ្លូវគមនាគមន៍ ។
- រិះរកមធ្យោបាយយ៉ាងណា ក្នុងការធ្វើអោយប្រសើរឡើង នូវការផ្លាស់ប្តូរពាណិជ្ជកម្ម រវាងប្រទេសទាំងបី ក្នុងតំបន់ត្រីកោណនេះ ។
- រិះរកមធ្យោបាយ អភិវឌ្ឍន៍វិស័យទេសចរណ៍ នៅប្រទេសទាំងបី ។
- រិះរកមធ្យោបាយធ្វើយ៉ាងណា ដើម្បីទប់ស្កាត់ជនអន្តោប្រវេសន៍ខុសច្បាប់ ។
- ពង្រឹងការឯកភាពគ្នា ក្នុងកិច្ចសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌប្រទេសអាស៊ាន ។

www.pheakdeylaw.com

- ពង្រឹងកិច្ចសហប្រតិបត្តិការទប់ស្កាត់ ការរត់ពន្ធគ្រឿងញៀន និងប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ។

**ប្រការ ៣** : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារកិច្ច និងសិទ្ធិ :

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំឯកសារកម្មវិធីនៃសកម្មភាព ក្នុងការគ្រប់គ្រង និងជំរុញកិច្ចសហប្រតិបត្តិការ ក្នុងទិសដៅអភិវឌ្ឍន៍តំបន់ត្រីកោណ តាមព្រំដែនប្រទេសទាំងបី កម្ពុជា-វៀតណាម-ឡាវ ។
- ចូលរួមប្រជុំ និងធ្វើទំនាក់ទំនងផ្ទាល់ ជាមួយក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ ខាងភាគីវៀតណាម និងឡាវ និងអង្គការអន្តរជាតិនានា ដើម្បីដោះស្រាយការងារពាក់ព័ន្ធ ។
- បង្កើតប្រតិទិនប្រចាំឆ្នាំមួយ សំរាប់អនុវត្តគំរោងផែនការ ដែលរដ្ឋាភិបាលនៃភាគីទាំងបីបានឯកភាពគ្នា ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល ដើម្បីសុំមតិណែនាំ និងគោលការណ៍ សំរេច ។

**ប្រការ ៤** : សមាជិកក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ ត្រូវចូលរួមប្រជុំតាមការអញ្ជើញនិងក្រោមការដឹកនាំរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីអវត្តមានរបស់ប្រធាន ។ ក្នុងករណីសមាជិកណាម្នាក់មិនបានអញ្ជើញចូលរួមប្រជុំ ដោយជាប់រវល់ភារកិច្ច ត្រូវចាត់តំណាងដែលមានសិទ្ធិសំរេច អោយចូលរួមជំនួស ។

**ប្រការ ៥** : ក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ មានលេខាធិការដ្ឋាន ដែលមានទីតាំងនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយមានសិទ្ធិប្រើប្រាស់ត្រាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមានសិទ្ធិអញ្ជើញអ្នកជំនាញឯកទេសមកពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អោយចូលរួមប្រជុំ ឬជួយបំពេញការងារក្នុងឋានៈជាជំនួយការ ខាងផ្នែកបច្ចេកទេស ។ លេខាធិការដ្ឋាននៃក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណនេះ ត្រូវដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍នៃក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ ។

www.pheakdeylaw.com

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួង សុខាភិបាល និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

## ៣-សារាចរ

## សារាចរណែនាំ លេខ ០១ សរណន

## ស្តីពីការរៀបចំ បែបបទស្នើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីជាការលើកទឹកចិត្ត ព្រមទាំងចារឹកទុកនូវគុណបំណាច់ និងស្នាដៃដ៏ខ្ពង់ខ្ពស់ក្នុងការការពារ និងកសាងប្រទេស រាជរដ្ឋាភិបាលធ្លាប់បានបំពាក់នូវគ្រឿងឥស្សរិយយសរបស់ជាតិគ្រប់ប្រភេទ ជូនចំពោះជនរួមជាតិ និងមិត្តភក្តិបរទេស ស្របទៅតាមទំហំស្នាដៃ និងគុណបំណាច់របស់បុគ្គលម្នាក់១ ឬសមូហភាពនិមួយ១ ។ គោលនយោបាយលើកទឹកចិត្ត និងផ្តល់កិត្តិយសខាងលើនេះ ត្រូវបានទទួលការអបអរសាទរពីគ្រប់មជ្ឈដ្ឋាន ។ ទន្ទឹមនឹងលទ្ធផលដ៏ល្អខាងលើនេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា នៅមានការខ្វះចន្លោះមួយចំនួនដែលចាំបាច់ត្រូវមានការកែលំអឡើងវិញ ដើម្បីអោយការផ្តល់គ្រឿងឥស្សរិយយស

www.pheakdeylaw.com